ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០០៤/២៤ គ.ប.ជ

# របាយការណ៍ខែវិច្ឆិកា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែធ្នូ ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍

ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី "**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

### ១.១. ការអប់រំដោយផ្ទាល់

#### ១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **១៣.៥៤៧**លើក មានអ្នកចូលរួមសរុបចំនួន **៦៦៥.៨១២**នាក់ (ធៀបនឹងខែតុលាមានចំនួន **៩១៣.១៣៣**នាក់ គឺមានថយចុះចំនួន **២៤៧.៣២១**នាក់ ស្មើនឹង **២៧,០៨%** ក្នុងនោះស្ត្រីចំនួន **៣៤២.៥៤៦**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ២៦៥ | ២៦.៩៤២ | ១៣.១៨៤ | ៦៦០ | ២៦.៩២៥ | ១៤.៨២៧ |
| | សរុប ក្រសួង ស្ថាប័ន | ២៦៥លើក | ២៦.៩៤២នាក់ | ១៣.១៨៤នាក់ | ៦៦០លើក | ២៦.៩២៥នាក់ | ១៤.៨២៧នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៧៥១ | ៥០.១៨២ | ២២.៩៤៥ | ១.៥១៥ | ៨៥.៩៧៩ | ៤៧.៥៣៨ |
| ៣ | ខេត្តបាត់ដំបង | ៧៩១ | ៣៧៦៤៤ | ២០.៨៨៦ | ៥៨៦ | ២០.៦១៦ | ១១.៨៦១ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៥៥ | ៣៤.៩៣៣ | ១៨.០០៣ | ១៥២ | ៥.៦០៤ | ២.៧៦០ |
| ៥ | ខេត្តសៀមរាប | ៥០០ | ៤២.៦២៦ | ២៦.៣៩៧ | ១៥០ | ៤.២០៤ | ២.៥០១ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧១៥ | ២០.១៤៨ | ១០.៥៤៨ | ៣៧២ | ១០.៤១០ | ៥.៣៨៣ |
| ៧ | ខេត្តកំពង់ចាម | ១.៨៧៩ | ១២៣.៦៤៦ | ៦០.០២៥ | ១៧៤ | ៣.៦៨០ | ១.៩១៦ |
| ៨ | ខេត្តព្រះសីហនុ | ១០២ | ៣.៤៨៥ | ១.៥៤៦ | ៨ | ៤៩៥ | ២២៣ |
| ៩ | ខេត្តព្រះវិហារ | ១៣ | ៩២៣ | ៣៨៧ | ៨ | ២.២៧៩ | ៧៦២ |
| ១០ | ខេត្តស្វាយរៀង | ៥ | ៤៧ | ២៥ | ៣៨៦ | ១៧.៤០០ | ៩.៨២៦ |
| ១១ | ខេត្តប៉ៃលិន | ៤ | ៦៤៥ | ៣៦៦ | ១ | ៦០ | ៣៩ |
| ១២ | ខេត្តកោះកុង | | | | ១០៦ | ២.៦២៩ | ១.៣៦២ |
| ១៣ | ខេត្តកំពត | ១ | ២៧៧ | ១៨០ | | | |
| ១៤ | ខេត្តកំពង់ធំ | ៥៧៥ | ៧០.៦៦៨ | ៤០.៧៤៤ | ៥៦ | ៧.៤០៤ | ១.៤៤៧ |
| ១៥ | ខេត្តតាកែវ | ៤៤៩ | ១៥.៣៩២ | ៨.០៣០ | ៣៦៥ | ១២.៤៤៩ | ១.៥៧៩ |
| ១៦ | ខេត្តក្រចេះ | ១៩ | ៧៤០ | ៤៨៣ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេតកំពង់សឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២១ | ខេត្តព្រៃវែង | ២០៧ | ១៩.២៨១ | ៩.៤៩២ | ៥ | ២៣០ | ១៨៨ |
| ២២ | ខេត្តត្បូងឃ្មុំ | ១.៩៨៦ | ២៦.៦៦២ | ១២.០៥៧ | ៦២ | ១.៩២៣ | ៧៨៧ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៧២៤ | ១១.៧៧៣ | ៦៤៧១ | ១៦០ | ៤.៤៣៦ | ២.៦០៥ |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៩.១៧៦លើក | ៤៥៩.០៧២នាក់ | ២៣៨.៥៨៥នាក់ | ៤.១០៦លើក | ១៧៩.៧៩៨នាក់ | ៩០.៧៧៧នាក់ |
| សរុបរួម | | ១៣.៥៤៧ លើក | | ៦៦៥.៨១២ នាក់ | | ៣៤២.៥៤៦ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តបន្ទាយមានជ័យ៖**
  - **មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍៖** បានធ្វើការផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **១.០៥៥**នាក់ (ស្រី **៨១៤**នាក់) អតីតពលករចំនួន **៣០៨**នាក់ (ស្រី **២៤៣**នាក់)។
  - **អង្គការកល្យាណមិត្ត** បានផ្សព្វផ្សាយបំណិនជីវិត ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **៣៩៨**នាក់។
  - **អង្គការតំណក់ទឹក** បានចុះធ្វើសកម្មភាពបណ្ណាល័យចល័ត អប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **៣៦**នាក់ (ស្រី **២៧**នាក់)។
  - **អង្គការសាម៉ារីតាន់ភឺស** បានអប់រំសហគមន៍អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ពលករចំនួន **៣៨៥**នាក់ (ស្រី **១១៨**នាក់) កុមារ **៣៧**នាក់ (កុមារី **១០**នាក់)។
  - **អង្គការ IOM** បានប្រឹក្សាយោបល់ដោយផ្ទាល់ជាលក្ខណៈឯកជន ជាមួយពលករវិលត្រលប់មានដូចជា៖ ១-ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពចំនួន **៣១**នាក់ (ស្រី **០៨**នាក់)។ ២-ឱកាសទទួលបានការងារក្នុងស្រុកចំនួន **២៣**នាក់ (ស្រី **០២**នាក់)។
- **ខេត្តសៀមរាប៖** អង្គការមូលនិធិអេ២១ បានធ្វើការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ នៅតាមសហគមន៍ចំនួន **១៤**លើក អ្នកចូលរួមចំនួន **១.៩៤១**នាក់ (ស្រី **១.៣៤៨**នាក់)។
- **ខេត្តត្បូងឃ្មុំ៖** រដ្ឋបាលស្រុកតំបែរ បានសហការជាមួយអង្គការ ប្រភពទឹកនៃសេចក្តីសង្ឃឹម រៀបចំវេទិកាសាធារណៈ ស្តីពីកាធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស ស្ថិតនៅភូមិផ្អាវ ឃុំទឹកជ្រៅ ស្រុកតំបែរ អ្នកចូលរួមចំនួន **១៨៥**នាក់ (ស្រី **៤៩**នាក់)។

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន **១.៤៤៨**ដង។
- **ខេត្តបន្ទាយមានជ័យ៖** អង្គការ IOM ពលករដែលទទួលបានព័ត៌មានពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព នៅសហគមន៍ចំនួន **៣២៩**នាក់ (ស្រី **២៥០**នាក់) និងប្រឹក្សាជាលក្ខណៈឯកជនភាពតាមរយៈទូរស័ព្ទ និងប្រព័ន្ធបណ្តាញសង្គមចំនួន **៦៦**នាក់ (ស្រី **២០**នាក់)។
- **លេខាធិការដ្ឋាន គ.ខ.ប.ជ** ផ្សព្វផ្សាតាមប៉ុស្តិ៍វិទ្យុ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសរុបចំនួន **២៧១**លើក មានខេត្តៈ (សៀមរាប **១៦១**លើក ព្រៃវែង **៥០**លើក កំពង់ឆ្នាំង **៦០**លើក)។

### ១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាវាគ្មិនកិត្តិយស ក្នុងសិក្ខាសាលា ស្តីពី តួនាទី នៃវិស័យវប្បធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរៀបចំឡើងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

### ១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ខេត្តសៀមរាប៖** វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បានចែកខិតប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជ្រើសរើសបេក្ខជនចូលរៀនជំនាញវិជ្ជាជីវៈ ចំនួន **៣ ៧១៦**ខិតប័ណ្ណ។
- **ខេត្តបន្ទាយមានជ័យ៖** អង្គការសាម៉ារីតាន់ភីស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ ចំនួន **៣.២៩៨**នាក់ (ស្រី **២.០៩០**នាក់) កុមារី **២៣៦**នាក់។
- **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភីស បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព **១.២៨៦**សន្លឹក ខិត្តប័ណ្ណទប់ស្កាត់ការជួញដូរមនុស្ស **១.០២៩**សន្លឹក និងខិត្តប័ណ្ណអប់រំពីការពារការរំលោភបំពានកុមារ តាមប្រព័ន្ធអនឡាញចំនួន **៦០០**សន្លឹក។
- **ខេត្តស្ទឹងត្រែង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការផ្សព្វផ្សាយអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋក្នុងពិធីរៀបចំបុណ្យអុំទូក អកអំបុក សំពះព្រះខែ ចំនួន **១០**បដា។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២២៣.៤៣៥**នាក់ (ស្រី **៩៩.១៤២**នាក់) អនីតិជន **៣.៥៣៥**នាក់ (ស្រី **១.២៣៤**នាក់)៖
  - ស្របច្បាប់ **១៦៨.៩១០**នាក់(ស្រី **៧៧.២០៤**នាក់)អនីតិជន **២៩០**នាក់(ស្រី **៨៦**នាក់)
  - មិនស្របច្បាប់ **៥៤.៣៥៥**នាក់(ស្រី**២១.៨៧៥**នាក់) អនីតិជន**៣.២៣៥**នាក់(ស្រី**១.១៤៤**នាក់)
  - ដាច់ការទាក់ទង **១៧០**នាក់ (ស្រី **៦៣**នាក់) អនីតិជន **១០**នាក់ (ស្រី **០៤**នាក់)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១២២.៥៧៩**នាក់ (ស្រី **៥៧.៥៦១**នាក់) អនីតិជន **៤៣៨**នាក់ (ស្រី **១៦៤**នាក់)។
- **ខេត្តបាត់ដំបង៖** កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានសហការជាមួយកម្លាំងជំនាញ នៃអធិការដ្ឋាននគរបាលស្រុកទាំង៤ជាប់ព្រំដែន ទប់ស្កាត់ពលករខ្មែរបានចំនួន **០១**លើក ឃាត់ពលករចំនួន **០៥**នាក់ (ស្រី **០៣**នាក់) អប់រំបញ្ជូនទៅលំនៅដ្ឋានវិញ។

### ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន **៩៥**គោលដៅ មនុស្សចំនួន **២៥៨**នាក់ (ស្រី **១៦៩**នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កំពត កោះកុង ក្រចេះ ព្រះវិហារ និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ២៩លើក។

**២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៨០នាក់(ស្រី ០៣នាក់) មាន១១សញ្ជាតិ រួមមានៈ ចិន ៤៩នាក់ អាមេរិក ១៥នាក់ កូរ៉េខាងត្បូង ០៨នាក់ (ស្រី ០២នាក់) បារាំង ០១នាក់ អូស្ត្រាលី ០១នាក់ ថៃ ០១នាក់(ស្រី) វៀតណាម ០១នាក់ អ៊ីតាលី ០១នាក់ បង់ក្លាដេស ០១នាក់ អេស្តូនី ០១នាក់ រូម៉ានី ០១នាក់ ។ បានវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយចំនួន ៧៤នាក់ (ស្រី ០៣នាក់)។ បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរដែលរៀបការ ទៅរស់នៅប្រទេសចិនចំនួន ០២នាក់។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុៈ**ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៥ករណី លើ១៣ករណី កើនឡើងចំនួន ០២ករណី ស្មើនឹង ១៥,៣៨% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្តចំនួន ១៨នាក់ (ស្រី ០៦នាក់) ជនសង្ស័យជាអនីតិជន ០៣នាក់ និងជាជនបរទេស ០១នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ៣៥នាក់ អាយុក្រោម១៥ឆ្នាំ ១២នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ១៧នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២១នាក់ និងប្រគល់ឱ្យគ្រួសារ ១៤នាក់) ក្នុងនោះចែកជាៈ

**១. ករណីអំពើជួញដូរមនុស្ស (គ្មានបទល្មើស)**

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ១៥ករណី/១០ករណី (កើនឡើង ០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៨នាក់ (ស្រី ០៦នាក់) ជាអនីតិជន ០៣នាក់ និងជាជនបរទេស ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៣៥នាក់ អាយុក្រោម១៥ឆ្នាំ ១២នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុ១៨ឆ្នាំឡើង ១៧នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២១នាក់ និងប្រគល់ឱ្យគ្រួសារ ១៤នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | បរទេស |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោស( ការចាប់ពង្រត់ ការឃុំឃាំង ឬបង្ខាំង | ០១ | ០២ | ០១ | វៀតណាម១ |
| -សញ្ចារកម្ម | ០១ | ០១ | ០១ | |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៣ | ២០ | ០៥ (អនី.០២) | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០៣ | ០៣ | ០៤ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | ០៤ (អនី.០១) | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៤ | ០៣ | |
| *សរុប* | *១៥ ករណី* | *៣៥ នាក់* | *១៨ នាក់* | *០១ នាក់* |

### ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

#### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

##### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួលជនរងគ្រោះដែលវិលត្រឡប់ពីប្រទេសចិនចំនួន **១៩**នាក់(ស្រី) លទ្ធផលសម្ភាសន៍ រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ។
  - **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ វៀតណាម និងឡាវបញ្ជូនត្រឡប់មកវិញចំនួន **៥១**លើក មនុស្សចំនួន **៩៣៨**នាក់ (ស្រី **២៤៧**នាក់) អនីតិជន **៧៣**នាក់ (ស្រី **២៩**នាក់) ក្នុងនោះមានៈ
    - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យចំនួន **៤៦**លើក មនុស្ស **៩១៥**នាក់ (ស្រី **២៣៣**នាក់) អនីតិជន **៦៥**នាក់ (ស្រី **២៦**នាក់)
    - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀងចំនួន **០១**លើក មនុស្ស **១១**នាក់ (ស្រី **០៧**នាក់) អនីតិជន **០៨**នាក់ (ស្រី **២៦**នាក់)
    - ស្នងការដ្ឋាននគរបាលខេត្តកោះកុងចំនួន **០៣**លើក មនុស្ស **០៦**នាក់ (ស្រី **០១**នាក់)។
    - ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែងចំនួន **០១**លើក មនុស្ស **០៦**នាក់(ស្រី)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** សហការរៀបចំដោយ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្ទឹងត្រែង និងឧបត្ថម្ភគាំទ្រ | ០១ | ៣៥ | ១៨ |

| | | | |
|---|---|---|---|
| ដោយ អង្គការអេស៊ានអាក់ និងអង្គការហោការ បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តស្ទឹងត្រែង។ | | | |
| **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការ ADRA បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីប៉ុស្តិ៍ និងប្រជាការពារ ស្តីពីការផ្តល់ប្រឹក្សាយោបល់ពាក់ព័ន្ធនឹងអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់។ | ០១ | ២៨ | ០៣ |
| **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការសុវណ្ណភូមិ ផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីការចំណាកស្រុកដោយសុវត្ថិភាពជាងមុន អំពើជួញដូរមនុស្ស និងការគ្រប់គ្រងថវិកាក្នុងគ្រួសារ។ | ០១ | ១៣ | |
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០២ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារធាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ០៧ | ១៤៥ | ៨៦ |
| **សរុប** | **១០ លើក** | **២២១ នាក់** | **១០៧ នាក់** |

## គ.២. សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - បានរៀបចំសិក្ខាសាលាថ្នាក់ជាតិ ការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) និងការបង្កើតផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០២៤-២០២៨) ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការក្រសួងការពារជាតិ រដ្ឋលេខាធិការក្រសួងព័ត៌មាន រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុរដ្ឋលេខាធិការក្រសួងផែនការ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាងក្រសួង ស្ថាប័នជាសមាជិក គ.ជ.ប.ជ និងអង្គការដៃគូ សរុបចំនួន **១០២**នាក់ (ស្រី **៤៧**នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។
  - បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីយន្តការណ៍បញ្ជូនបន្តថ្នាក់ជាតិ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានការអញ្ជើញចូលរួមពី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុរដ្ឋលេខាធិការក្រសួងផែនការ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ អគ្គលេខាធិការ គ.ជ.ប.ជ អគ្គស្នងការរងនគរបាលជាតិ ព្រះរាជអាជ្ញារង នៃអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ និងតំណាងក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គការជាដៃគូ សរុបចំនួន **៥៤**នាក់ (ស្រី **២១**នាក់) ក្រោមការឧបត្ថម្ភគាំទ្រពី អង្គការ IOM នៅសណ្ឋាគារ កាំបូឌីយ៉ាណា។

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១. សន្និសីទ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អមដំណើរដោយ លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងសន្និសីទថ្នាក់តំបន់ ស្តីពីអំពើពុករលួយពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធជនទេសន្តរប្រវេសន៍ ដែលប្រព្រឹត្តទៅចំនួន២ថ្ងៃ នាទីក្រុងបាងកក ប្រទេសថៃ។

### ២.២. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ២.២.១ កិច្ចប្រជុំក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
  - បានទទួលជួបប្រជុំពិភាក្សាការងារជាមួយ **កញ្ញា គ្រីស្ទីន** នាយិកាអង្គការមូលនិធិអេ២១ ដើម្បីពិនិត្យខ្សែភាពយន្តអប់រំ ក្រោមចំណងជើង តើអ្នកឃើញខ្ញុំទេ? សមាសភាពចូលរួមមាន លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ លោកប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ លោកប្រធាន C.A.C នៃអង្គការមូលនិធិអេ២១ នៅសាសប្រជុំ គ.ជ.ប.ជ។
  - បានដឹកនាំកិច្ចប្រជុំចង្អៀត ស្តីពីកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ ដើម្បីត្រៀមឆ្លើយតបទៅនឹងអនុសាសន៍ របស់សហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការដាក់ចំណាត់ថ្នាក់ នៃការអនុវត្តផែនការសកម្មភាពប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា សមាសភាពចូលរួមមាន លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងអគ្គនាយដ្ឋានអន្តោប្រវេសន៍ តំណាងអគ្គនាយអគ្គសញ្ញាណកម្ម តំណាងនាយកដ្ឋានកណ្តាលសន្តិសុខ តំណាងនាយកដ្ឋានអគ្រានុកូលដ្ឋាន នៅសាលប្រជុំ គ.ជ.ប.ជ។
- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - សហការជាមួយអង្គការ IOM បានបើកកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិ ធ្វើការពិនិត្យ និងសម្រេចផែនការជាតិសម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដឹកនាំកិច្ចប្រជុំពិភាក្សាដោយ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកស្រី **គ្រីស្ទាន ផាកូ** ប្រធានអង្គការ IOM ដែលមានការចូលរួមពីលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ និងអន្តរជាតិ សរុបចំនួន **៥៧**នាក់ នៅសណ្ឋាគារ SUN & MOON។
  - បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ត្រូវបានរាជរដ្ឋាភិបាលកំណត់យកថ្ងៃទី២០ ខែសីហារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

សមាសភាពចូលរួមមាន ក្រសួងធម្មការនិងសាសនា ក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ IOM AIM Nomi Network CWCC OJC Hagar Chab Dai Caritas Cambodia សរុបចំនួន **១៩**នាក់ (ស្រី **០៥**នាក់)។

- បានរៀបចំកិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីការត្រៀមរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សមាសភាពចូលរួមដែលជាតំណាង រួមមាន៖ លេខាធិការដ្ឋានសម្តេចព្រះមហាសង្ឃរាជ សាសនាឥស្លាមកម្ពុជា ព្រះសហគមន៍កាតូលិក ប្រិយសម្ព័ន្ធគ្រីស្ទបរិស័ទ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នាយកដ្ឋានអង្គរក្ស សាលារាជធានីភ្នំពេញ អង្គការ AIM ASEAN-Act Caritas Cambodia Chab Dai CWCC ERIKS IJM IOM LSCW និងអង្គការ Marici សរុបចំនួន **៤៣**អង្គ/នាក់ (ស្រី **១៥**នាក់)។

### ខ.២.២ កិច្ចប្រជុំក្រៅប្រទេស

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ ឧត្តមសេនីយ៍ទោ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ កម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ស្តីពីការសម្រេចសិទ្ធិ និងឱកាសរបស់ពលករទេសន្តរប្រវេសន៍ ជាស្ត្រី នៅក្នុងតំបន់អាស៊ាន (២០១៨-២០២៣) ប្រព្រឹត្តទៅចំនួន២ថ្ងៃ នៅសណ្ឋាគារ Pullman Bangkok ប្រទេសថៃ រៀបចំដោយ អង្គការ UN Women គាំទ្រដោយសភាពអ៊ឺរ៉ុប EU និងអង្គការ ILO សមាសភាពចូលរួមពីបណ្តាប្រទេសមាន កម្ពុជា ថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន និងលេខាធិការដ្ឋានអាស៊ាន សរុបចំនួន **១០០**នាក់។

## ខ.២. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
  - បានទទួលជួបពិភាក្សាការងារ ជាមួយតំណាងផ្នែកគោលនយោបាយ នៃស្ថានទូតអាម៉េរិក ប្រចាំនៅកម្ពុជា អំពីរបៀបវារៈដែលភាគីស្ថានទូតអាម៉េរិក ស្នើដាក់បញ្ចូលសម្រាប់កិច្ចប្រជុំរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានទូតអាម៉េរិក ស្តីពីរបាយការណ៍ប្រឆាំងការជួញដូរមនុស្សរបស់សហរដ្ឋអាម៉េរិក។
  - បានដឹកនាំមន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលបដិសណ្ឋារកិច្ច លោកជំទាវ Cyndy Dyer ឯកអគ្គរដ្ឋទូតជាន់ខ្ពស់នៃសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការប្រឆាំងការជួញដូរមនុស្ស ដើម្បីសិក្សាបន្ថែមអំពីបទពិសោធន៍ការងាររបស់ គ.ជ.ប.ជ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នដែលជាសមាជិកនៃគ.ជ.ប.ជ ទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ធ្វើឡើងក្នុងគោល

បំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាព នៃការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងការអនុវត្តអនុសាសន៍របស់សហរដ្ឋអាមេរិក ដែលបានដាក់ជូនមករាជរដ្ឋាភិបាលកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។

- **ខេត្តត្បូងឃ្មុំ៖** លោកជំទាវ **នី ចាន់ធីតា** អភិបាលរងខេត្ត បានដឹកនាំក្រុមលេខាធិការដ្ឋាន និងក្រុមការងារជំនាញទាំង ០៦ ជួបពិភាក្សាការងារជាមួយអង្គការណូមីណេតវើកកម្ពុជា តំណាងដោយលោក **វ៉ុង រតនា** នាយកប្រចាំប្រទេស ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៣៤**លើក មានអ្នកចូលរួមសរុប **៦៤៤**នាក់ (ស្រី **២៥៤**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១៣**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **២១**លើក។**(ឧបសម្ព័ន្ធ១)**

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែធ្នូ ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ ចន្ទ ១២រោច ខែមិគសិរ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមករា ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ម៉ិនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៤លើក) មនុស្សចំនួន ៦៤៤នាក់ (ស្រី ២៥៤នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញដឹកកិច្ចប្រជុំ ស្តីពីការបែងចែកភារកិច្ច សម្រាប់ការរៀបចំទិវាជាតិ ១២ធ្នូ ២០២៣ ជាមួយក្រុមពិធីការក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៣៤ច្បាប់ លិខិតចូល ៣៧ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១០ច្បាប់ លិខិតចូល ៣៧ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែវិច្ឆិកា ឆ្នាំ២០២៣ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៨៣ច្បាប់។<br>- ស្រាវជ្រាវព័ត៌មាន ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៤៦ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន៣៣សកម្មភាព។<br>- អាប់ឡូតឯកសារបណ្ណាល័យវីគីបានចំនួន០៩ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានដឹកនាំប្រជុំក្រុមការងារព័ត៌មានវិទ្យា រូបភាព បទយកការណ៍ និងផ្សព្វផ្សាយ ដើម្បីត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៣។ |

| | |
|---|---|
| | - លោកប្រធានក្រុម បានចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តគម្រោងគាំទ្រ និងការពារជនរងគ្រោះរួចផុតជីវិតដោយអំពើជួញដូរមនុស្ស រួមទាំងការបោកបញ្ឆោតតាមប្រព័ន្ធអនឡាញនៅកម្ពុជា រៀបចំដោយអង្គការការីតាសកម្ពុជា។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- លោកប្រធានក្រុម<br>○ បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់លើសេចក្ដីព្រាងរបាយការណ៍ជាសកល សម្រាប់ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ។<br>○ បានចូលរួមប្រជុំពិភាក្សាកែសម្រួលលើរបៀបវារៈ នៃការដាក់ឱ្យប្រើប្រាស់សៀវភៅគោលនយោបាយជាតិ ស្ដីពីសុខភាពជនទេសន្តរប្រវេសន៍ នៅក្រសួងសុខាភិបាល។<br>○ បានចូលរួមធ្វើគ្រូឧទ្ទេសដល់មន្ត្រីជួរមុខ ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប នៅខេត្តស្ទឹងត្រែង។<br>○ បានចូលរួមកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពីទេសន្តរប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្សនៅអាស៊ី នៅខេត្តសៀមរាប។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្ដីពីវឌ្ឍនភាព បញ្ហាប្រឈម និងពិភាក្សាអំពីការអនុវត្តបន្ត នៃអនុសាសន៍របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ នៃអង្គការសិទ្ធិមនុស្ស រៀបចំដោយ CNCC & UNICEF នៅសណ្ឋាគារ កាំបូឌីយ៉ាណា។<br>○ បានអញ្ជើញដឹកនាំកិច្ចប្រជុំស្ដីពីការបែងចែកភារកិច្ច សម្រាប់ការរៀបចំទិវាជាតិ ១២ធ្នូ ២០២៣ ជាមួយក្រុមពិធីការក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។<br>- លោកប្រធានក្រុម បានចូលរួមកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (RTF) និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១៥ (SOM15)។<br>- លោកស្រីអនុប្រធានក្រុម បានចូលរួមកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពីទេសន្តរប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្សនៅអាស៊ី នៅខេត្តសៀមរាប។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងកម្មវិធីបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្ដីពីទេសន្តរប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្សនៅអាស៊ី ខេត្តសៀមរាប។<br>- លោកអនុប្រធានក្រុម បានជួបពិភាក្សាជាមួយតំណាងអង្គការ IJM អំពីការរៀបចំផែនការបើកវគ្គបណ្ដុះបណ្ដាល ស្ដីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប ដែលត្រៀមធ្វើនៅ ខេត្តបាត់ដំបង ឧត្តរមានជ័យ និងកោះកុង នាពេលមុខនេះ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២១លើក អ្នកចូលរួមសរុបចំនួន ៦៤៤នាក់ (ស្រី ២៥៤នាក់)** | |

| | |
|---|---|
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែតុលាចំនួន០១លើក អ្នកចូលរួមចំនួន២៨នាក់ ស្រី១៩នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែតុលា ចំនួន០៦លើក អ្នកចូលរួមចំនួន១៤០នាក់ ស្រី៦៥នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែវិច្ឆិកាចំនួន០១លើក ដើម្បីធ្វើការតាមដាន ត្រួតពិនិត្យអ្នកចូលរួមចំនួន៦៣នាក់ ស្រី៣៧នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ ដើម្បីធ្វើការតាម ដានត្រួតពិនិត្យចំនួន០៨លើក អ្នកចូលរួមចំនួន១៩៩នាក់ ស្រី៩៤នាក់។ |
| **ខេត្តកំពត** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានថ្មីៗ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០១លើក អ្នកចូលរួមចំនួន ២៩នាក់ ស្រី១៥នាក់។ |
| **ខេត្តព្រៃវែង** | - រដ្ឋបាលខេត្ត បានរៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ដើម្បីពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ ផ្សព្វផ្សាយការងារភូមិ-ឃុំ មានសុវត្ថិភាព ចំនួន០១លើក អ្នកចូលរួមចំនួន១០៣នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - រដ្ឋបាលស្រុក បានរៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាព ដើម្បីពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់ និងផ្សព្វផ្សាយច្បាប់ ស្តីពីការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន០៣លើក អ្នកចូលរួមចំនួន៨២លើក ស្រី២៤នាក់។ |